# ច្បាប់ស្តីពីការចូលរួមសកម្មភាពរបស់មាតាបិតាទូទាំងក្រសួងសម្រាប់ឆ្នាំ២០១០

* * * * *

## <u>ជំពូក ១.</u> <u>គោលចំណងជាទូទៅ</u>

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** (SPD) យល់ព្រមអនុវត្ត តម្រូវការតាមលក្ខន្តិកៈ ដូចតទៅ៖

- ក្រសួងអប់រំនឹងចាប់ផ្តើមប្រតិបត្តិនូវ កម្មវិធី សកម្មភាព និង វិធីផ្សេងៗ សម្រាប់ការចូលរួមរបស់ មាតាបិតា/អាណាព្យាបាល ក្នុងសាលាទាំងអស់របស់ក្រសួងអប់រំ ដែលស្របតាមមាត្រាលេខ ១១១៨ នៃច្បាប់ អប់រំថ្នាក់បឋមភូមិ និង ទុតិយភូមិ (Elementary and Secondary Education Act, ESEA) កម្មវិធី Title I, Part A។ កម្មវិធី សកម្មភាព និង វិធីទាំងនោះ នឹងត្រូវបានគេរៀបចំ និង អនុវត្ត ដោយមានការពិភាក្សាជាមួយមាតាបិតា/អាណាព្យាបាលព្យាបាល របស់ក្មេងដែលចូលរួមក្នុងកម្មវិធីនេះ។

- ស្របតាមមាត្រាលេខ ១១១៨ ក្រសួងអប់រំនឹងសហការជាមួយសាលាទាំងអស់របស់ក្រសួង ដើម្បីធ្វើ យ៉ាងណាឲ្យច្បាប់នៃកម្រិតការចូលរួមសកម្មភាពសាលារបស់មាតាបិតា ត្រូវតាមការតម្រូវរបស់ មាត្រាលេខ ១១១៨(b) នៃច្បាប់ ESEA ហើយច្បាប់នីមួយៗមានរួម សមាសភាគ កិច្ចសន្យារវាង មាតាបិតា និង សាលា ស្របតាមមាត្រាលេខ ១១១៨(d) នៃច្បាប់ ESEA។

- ក្នុងការអនុវត្តន៍ច្បាប់ Title I, Part A ការតម្រូវនៃការចូលរួមរបស់មាតាបិតា តាមតែអាចធ្វើទៅបាន ក្រសួងអប់រំ និង សាលាទាំងអស់ នឹងផ្តល់ឱកាសចូលរួមយ៉ាងពេញទំហឹង ដល់មាតាបិតា/អាណាព្យាបាល ដែលចេះភាសាអង់គ្លេសតិចតួច មាតាបិតា/អាណាព្យាបាល ដែលពិការ និង មាតាបិតា/អាណាព្យាបាល របស់ក្មេងអន្តោប្រវេសន៍ រួមទាំងការផ្តល់ព័ត៌មាន និង របាយការណ៍សាលា ដែលបានតម្រូវដោយមាត្រាលេខ ១១១១ នៃច្បាប់ ESEA តាមទម្រង់ និងលក្ខណៈដូចគ្នា ដែលអាចយល់បាន ហើយរួមទាំងទម្រង់ផ្សេងៗទៀត តាមការស្នើសុំ និងតាមតែអាចធ្វើទៅបាន ជាភាសាដែលមាតាបិតា/អាណាព្យាបាល អាចយល់បាន។

- ក្រសួងអប់រំនឹងរួមសហការជាមួយមាតាបិតា/អាណាព្យាបាលរបស់ក្មេង ដែលទទួលជំនួយពី Title I, Part A ក្នុងការសម្រេចនូវការចំណាយ១ភាគរយ នៃប្រាក់ជំនួយ Title I, Part A ថាតើត្រូវចាយដោយរបៀបណា សម្រាប់ការចូលរួមរបស់មាតាបិតា និងធ្វើយ៉ាងណាមិនឲ្យតិចជាង៩៥ភាគរយ នៃប្រាក់ជំនួយ១ភាគរយនេះ ឲ្យទៅសាលា សម្រាប់ចំណាយទៅលើសកម្មភាពផ្សេងៗដែលទាក់ទងនឹងមាតាបិតា ឬ សម្រាប់សកម្មភាពរបស់សាលារៀន តាមកិច្ចព្រមព្រៀង រវាងមាតាបិតា និង អភិបាលសាលារៀន។

- ក្រសួងអប់រំនឹងត្រូវអនុវត្តតាមអត្ថន័យនៃលក្ខន្តិកៈ អំពីការចូលរួមរបស់មាតាបិតា ដូចតទៅនេះ ហើយសង្ឃឹមថា សាលាទាំងអស់ដែលទទួលជំនួយពី Title I នឹងមាន កម្មវិធី សកម្មភាព និង វិធី ផ្សេងៗ ដែលស្របតាម អត្ថន័យទាំងនេះ៖

*ការចូលរួមរបស់មាតាបិតា មានន័យថា ជាការចូលរួមតាមធម្មតា របស់មាតាបិតា/អាណាព្យាបាល ទំនាក់ទំនងទៅវិញទៅមក និង មានអត្ថន័យ ដែលទាក់ទងដល់ការសិក្សារបស់សិស្ស និង សកម្មភាពសាលាផ្សេងៗទៀត ដែលរួមទាំង_*

*(ក) មាតាបិតា/អាណាព្យាបាល មានមុខងារយ៉ាងសំខាន់ ក្នុងការជួយដល់ការសិក្សារបស់កូន*

*(ខ) មាតាបិតា/អាណាព្យាបាល ត្រូវទទួលការលើកទឹកចិត្ត ឲ្យចូលរួមយ៉ាងសកម្ម ក្នុងការសិក្សារបស់កូននៅសាលារៀន*

*(គ) មាតាបិតា/អាណាព្យាបាល ជាដៃគូគ្រប់កិច្ចការ ក្នុងការសិក្សារបស់កូន និង រួមទាំងការសម្រេចចិត្ត និង ជាក្រុមប្រឹក្សា ដើម្បីជួយដល់ការសិក្សារបស់កូន*

*(ឃ) អនុវត្តសកម្មភាពផ្សេងៗ ដូចជា អ្វីៗដែលបានរៀបរាប់ក្នុងមាត្រា ១១១៨ នៃច្បាប់ ESEA។*

## ជំពូក ២ ការរៀបរាប់អំពីវិធីដែលក្រសួងអប់រំនឹងអនុវត្ត តាមការតម្រូវ នៃច្បាប់ចូលរួមរបស់មាតាបិតា ទូទាំងក្រសួង

១. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា** នឹងមានសកម្មភាពដូចខាងក្រោមនេះ ដើម្បីឲ្យមាតាបិតា/អាណាព្យាបាល ចូលរួមក្នុងការអភិវឌ្ឍន៍រួមគ្នា នៃគម្រោងការចូលរួមរបស់មាតាបិតា ទូទាំងក្រសួង ក្រោមមាត្រាលេខ ១១១២ នៃច្បាប់ ESEA៖

- ឲ្យ Title I ក្រុមប្រឹក្សាមាតាបិតា (PAC) ទូទាំងក្រសួង ចូលរួមក្នុងការពិភាក្សាអំពីគម្រោងការ នៃការចូលរួមរបស់មាតាបិតា។
- អញ្ជើញមាតាបិតារបស់ក្រសួងទាំងអស់ចូលរួម តាមរយៈកម្មវិធី មាតាបិតាជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា (Parents Are “R” Equal Partners) ឲ្យចូលរួមក្នុងការពិភាក្សា អំពីគម្រោងការចូលរួមរបស់មាតាបិតា របស់ក្រសួងអប់រំ

២. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា** នឹងមានសកម្មភាពដូចខាងក្រោមនេះ ដើម្បីឲ្យមាតាបិតា/អាណាព្យាបាល ចូលរួមក្នុងវិធី ពិនិត្យមើល និង កែលម្អសាលា ក្រោមមាត្រាលេខ ១១១៦ នៃច្បាប់ ESEA៖

- ផ្ញើពាក្យណែនាំ (ចុះហត្ថលេខាដោយអគ្គនាយិកាក្រសួងអប់រំ) ទៅអគ្គនាយកតំបន់ និង នាយកសាលា អំពីការតម្រូវនេះនៅ ថ្ងៃទី១៥ ខែកញ្ញា ជារៀងរាល់ឆ្នាំ។

- អ្នកតំណាងច្បាប់ Title I អាចធ្វើការជាមួយអ្នកដឹកនាំមាតាបិតា និង បុគ្គលិកការិយាល័យទំនាក់ទំនងជាមួយមាតាបិតា និង ក្រុមគ្រួសារ ដើម្បីផ្តល់ការហ្វឹកហ្វឺនដល់ ក្រសួង តាមតំបន់ និង សាលា អំពីផ្នែកផ្សេងៗ នៃច្បាប់ Title I។
- សាលានឹងបង្កើតវិធីផ្សេងៗ ដែលជាមធ្យោបាយដើម្បីទទួល យោបល់ និង ហត្ថលេខា ពីមាតាបិតា ដែលមិនមែនជាបុគ្គលិកសាលា អំពីគម្រោងការនៃសកម្មភាពសាលា (ពីមុនហៅថា គម្រោងការកែលម្អសាលារៀន) ក្រុមប្រឹក្សាសាលា គឺជាមធ្យោបាយមួយ ដើម្បីបង្កើនការចូលរួម និង ការទទួលខុសត្រូវរបស់មាតាបិតា ក្នុងគម្រោងការនៃសកម្មភាព (កែលម្អ) សាលា។
- ផ្តល់ព័ត៌មានជាមុន ដែលមានរយៈពេលគ្រប់គ្រាន់ ដល់មាតាបិតា អំពីអង្គប្រជុំ និងការលប់អង្គប្រជុំ តាមលិខិតសារព័ត៌មាន តាមរយៈសមាគមមាតាបិតានិងសាលារៀន ចុះនៅលើក្តារខៀនផ្សាយព័ត៌មាន (រួមទាំងតាមអេឡិចត្រូនិច) តាមទូរស័ព្ទ និង ក្នុងលិខិតផ្ញើទៅផ្ទះ
- ផ្តល់ការបកប្រែភាសាដល់មាតាបិតា/អាណាព្យាបាល ដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត ដែលមានរួមទាំង សេចក្តីសង្ខេបនៃគម្រោងសកម្មភាពសំខាន់ៗ គម្រោងសកម្មភាព (កែលម្អ) សាលា សំខាន់ៗ ជាភាសាចម្បងៗ ៨ របស់ក្រសួងអប់រំ តាមតែអាចធ្វើទៅបាន ព្រមទាំងជំនួយពីបុគ្គលិកដែលចេះពីរភាសា នៅតាមកន្លែងនីមួយៗ។

គ. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងផ្តល់ជំនួយដែលចាំបាច់ដូចមានខាងក្រោមនេះ ការសម្របសម្រួលជំនួយបច្ចេកទេស និងការគាំទ្រផ្សេងៗទៀត ដើម្បីជួយដល់សាលារៀនដែលបានទទួលជំនួយ Title I, Part A ក្នុងការរៀបគម្រោង និង ការអនុវត្តសកម្មភាពចូលរួមរបស់មាតាបិតាដែលមានប្រសិទ្ធិភាព ដើម្បីបង្កើនជោគជ័យ ក្នុងការសិក្សា និង ការរៀនសូត្រនៅសាលារបស់សិស្ស៖

- សហការជាមួយអ្នកទាក់ទងផ្នែក NCLB នៅក្រសួងអប់រំ អ្នកទាក់ទងផ្នែក NCLB ក្នុងតំបន់ អ្នកធ្វើទំនាក់ទំនងជាមួយមាតាបិតា តាមតំបន់ និង តាមសាលា អ្នកទាក់ទងរវាងសហគមន៍និងសាលា ក្រុមប្រឹក្សាសាលានិងមាតាបិតានៅក្រុងហ្វីឡាដែលហ្វ្យា (PHSC) ក្រុមប្រឹក្សាមាតាបិតាផ្នែកច្បាប់ Title I ក្រុមជំនុំផ្នែកសិទ្ធិក្នុងការសិក្សានៅក្រុងហ្វីឡាដែលហ្វ្យា សិទ្ធិអំណាចរបស់មាតាបិតា (PARENT POWER) និង ក្រុមមាតាបិតាផ្សេងៗទៀត ផ្តល់សិក្ខាសាលាដល់សាលា អំពីការចូលរួមរបស់មាតាបិតា។

- ផ្តល់ការហ្វឹកហ្វឺនផ្នែកកិច្ចការងារ <u>ដោយ មាតាបិតា/អាណាព្យាបាល</u> សម្រាប់ នាយកសាលាថ្មី ឬ នាយកសាលាបច្ចុប្បន្ន និង អភិបាលដទៃទៀត អំពីវិធីដែលអាចឲ្យ មាតាបិតា/អាណាព្យាបាល ចូលរួមដោយប្រសិទ្ធិភាព។

- ហ្វឹកហ្វឺន បុគ្គលិកថ្មី និង បុគ្គលិកបច្ចុប្បន្ន អំពីភារកិច្ចនៃការធ្វើទំនាក់ទំនងជាមួយមាតាបិតា (ដូចជា អ្នកធ្វើទំនាក់ទំនងជាមួយមាតាបិតា អ្នកទំទាក់ទងរវាងសហគមន៍និងសាលា អ្នកសម្របសម្រួលជាមួយសហគមន៍ របស់សាលា និង អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា) ឲ្យជួយសាលា ក្នុងការធ្វើទំនាក់ទំនងជាមួយមាតាបិតា។

- រៀបចំឲ្យមានបុគ្គលិកពី ការិយាល័យសមភាពផ្នែកអប់រំ ការិយាល័យផ្នែកកម្មវិធីសិក្សាពិសេស សេវាគាំទ្រសិស្ស និង ការិយាល័យទំនាក់ទំនងជាមួយមាតាបិតា ក្រុមគ្រួសារ សហគមន៍ និងការសហការជាមួយក្រុមសាសនា និងបុគ្គលិកប្រចាំតំបន់ សម្រាប់ផ្តល់ជំនួយផ្នែកបច្ចេកទេស។

- ការិយាល័យផ្នែកប្រាក់ជំនួយ Title I និងផ្តល់ជំនួយបច្ចេកទេសដល់សាលា និងអង្គការរបស់មាតាបិតា ដូចជា ក្រុមប្រឹក្សាមាតាបិតា សម្រាប់ Title I (PAC) សមាគមសាលានិងមាតាបិតា ក្រុមជំនុំផ្នែកសិទ្ធិក្នុងការសិក្សានៃក្រុងហ្វីឡាដែលហ្វ្យា សិទ្ធិអំណាចរបស់មាតាបិតា និង ក្រុមមាតាបិតាផ្សេងៗទៀត។

- ផ្តល់ការចាត់ចែងក្នុងការហ្វឹកហ្វឺនផ្នែកកិច្ចការងារ តាមរយៈ ការិយាល័យគាំទ្រផ្នែកកម្មវិធីសិក្សា និងការដឹកនាំ។ ការអភិវឌ្ឍន៍កម្មវិធីសិក្សា។

- ផ្តល់សិក្ខាសាលាដល់មាតាបិតា អំពីការជួយសិស្សអោយទទួលបានជោគជ័យ និងអំពីការធ្វើទំនាក់ទំនងជាមួយមាតាបិតា។

- ផ្តល់សិក្ខាសាលាដល់មាតាបិតាដែលស្ម័គ្រចិត្ត អំពីសន្តិសុខនៅសាលា វប្បធម៌ផ្សេងៗគ្នា វិធីដោះស្រាយជម្លោះ កាបម្រើភ្ញៀវ និងអ្វីៗផ្សេងទៀត ទៅតាមការស្នើសុំ។

- ផ្តល់ការហ្វឹកហ្វឺន និង ព័ត៌មានផ្សេងៗទៅ ក្រុមប្រឹក្សាសាលា (SACs)។ នៅខែកញ្ញា ឆ្នាំ២០១០ ក្រុមប្រឹក្សាសាលានីមួយៗ នឹងលើកឡើងពីចំណុចសំខាន់ៗ ពីវិធីដែលពួកគេគ្រោងដើម្បីធ្វើការជាមួយមាតាបិតា នៃ Title I PREP ដើម្បីគំណត់ពេលហ្វឹកហ្វឺនការបង្វិលទិសដៅ សម្រាប់មាតាបិតាដែលនៅក្នុងសាលារបស់ពួកគេ។

- មាតាបិតា PREP ប្រចាំតំបន់ នឹងធ្វើជាទីប្រឹក្សារបស់ នាយកសាលា និង សមាជិកក្រុមប្រឹក្សាសាលា ពីវិធីដើម្បីលើកឡើងពីសេចក្តីត្រូវការរបស់សិស្ស និង មាតាបិតា នៅក្នុងគម្រោងសកម្មភាព និង ថវិការ របស់សាលា។

- ដើម្បីឲ្យស្របតាម ការគិតដល់ឆ្នាំ២០១៤ ត្រូវរៀបចំឲ្យ មាតាបិតា និង ក្រុមគ្រួសារ អាចជួបជាមួយ គ្រូបង្រៀន និង នាយកសាលា។

៤. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងរៀបចំ ហើយរួមបញ្ចូលផែនការនៃការចូលរួមសកម្មភាពរបស់មាតាបិតា នៅក្នុង Title I, Part A ជាមួយនិងផែនការនៃការចូលរួមរបស់មាតាបិតា នៅក្នុងកម្មវិធីផ្សេងៗ ដូចតទៅ៖ Head Start, Reading First, Comprehensive Early Learning Center (មណ្ឌលក្មេងចូលរៀនមុនពេលគ្រប់អាយុចូលសាលា), Bright Future (អនាគតភ្លឺថ្លា), Even Start (ចាប់ផ្តើមស្មើគ្នា) និង Cradle to Classroom (ពីក្នុង អង្រឹងទៅថ្នាក់រៀន) ដោយ៖

- មានអង្គប្រជុំជារៀងរាល់ត្រីមាស រវាង ការិយាល័យអប់រំមុនថ្នាក់មត្តេយ្យ និង ការិយាល័យទំនាក់ទំនងជាមួយមាតាបិតា និង ក្រុមគ្រួសារ ជាការិយាល័យដែលទទួលខុសត្រូវក្នុងការទាក់ទងជាមួយមាតាបិតា ទូទាំងក្រសួង រួមទាំងការរៀបចំអ្នកតំណាងមាតាបិតា ដែលមកពី កម្មវិធី និង សមាគម ផ្សេងៗ ឲ្យចូលរួម។ សេចក្តីរាយការណ៍កំណត់ហេតុនៃអង្គប្រជុំទាំងនេះនឹងមានជូន នៅពេលណាមានការស្នើសុំ។

- រៀបចំ ការហ្វឹកហ្វឺន ឬ ការថ្លែងពន្យល់ ដែលធ្វើឡើងរួមគ្នា សម្រាប់មាតាបិតា មុនពេលឆ្នាំសិក្សាថ្មីចាប់ផ្តើម អំពីការផ្លាស់ប្តូរកូនរបស់គាត់ ពីថ្នាក់មុនមត្តេយ្យ ទៅថ្នាក់មត្តេយ្យ និង អន្តរាគមន៍ដែលមានជោគជ័យ ដែលអាចប្រើនៅផ្ទះ។

- នាំឲ្យក្រុមមាតាបិតា ពីកម្មវិធីមុនថ្នាក់មត្តេយ្យតាមការថ្លែងពន្យល់ ទៅក្រុមគ្រួសារ ដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត។

៥. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងធ្វើការវាយតម្លៃប្រចាំឆ្នាំ ដោយមានការចូលរួមពី មាតាបិតា/អាណាព្យាបាល អំពី មាតិកា និង ប្រសិទ្ធិភាព នៃច្បាប់ចូលរួមរបស់មាតាបិតានេះ ដើម្បីធ្វើការវាយតម្លៃពីឥទ្ធិពលទៅលើការចូលរួមរបស់ក្រុមគ្រួសារ នៅសាលាដែលទទួលជំនួយ Title I, Part A។ ការវាយតម្លៃនឹងមាន រួមបញ្ចូលទាំងការស្វែងយល់ពីឧបសគ្គដែលរារាំងមិនឲ្យ មាតាបិតា/អាណាព្យាបាល ចូលរួមសកម្មភាពបានច្រើន (ជាពិសេសចំពោះមាតាបិតាដែលក្រខ្សត់ ពិការភាព ចេះភាសាអង់គ្លេសតិចតួច មានការចេះដឹងតិចតួច ឬ ជាសាសន៍ ឬ ជនជាតិភាគតិច)។ ក្រសួងអប់រំនឹងយកអ្វីដែលបានរកឃើញពីការវាយតម្លៃ នៃការចូលរួម និង សកម្មភាពផ្សេងៗ របស់មាតាបិតា ដើម្បីរៀបចំផែនការឲ្យកាន់តែមានប្រសិទ្ធិភាព និងដើម្បីធ្វើការកែសម្រួល ច្បាប់ចូលរួមរបស់មាតាបិតាឡើងវិញ បើសិនជាចាំបាច់ (ដោយមានការចូលរួមពីមាតាបិតា/អាណាព្យាបាល)។

គោលបំណងសំខាន់ៗនៃច្បាប់ចូលរួមរបស់មាតាបិតា គឺដើម្បីបង្កើនឲ្យមានការចូលរួមពីមាតាបិតា នៅក្នុងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ នៅក្នុងគោលបំណងដ៏សំខាន់នេះ មានគោលបំណងតូចៗបីដែលគេបានរកឃើញ ដូចតទៅ៖

ក) អញ្ជើញមាតាបិតាឲ្យជួយផ្តល់យោបល់អំពី ច្បាប់និងវិធី ទៅឲ្យក្រសួងអប់រំ
ខ) ធ្វើឲ្យមាតាបិតាមានការងាយស្រួល ក្នុងការស្វែងយល់ពី សាលា និង ធនធានផ្នែក អប់រំ និង សម្ភារៈ និង
គ) ផ្តល់ឱកាសដល់មាតាបិតា ក្នុងការទទួលព័ត៏មានឲ្យបានច្រើនអំពី ជោគជ័យនៃការសិក្សា និង ការរកជំនួយផ្សេងៗ សម្រាប់ជួយដល់ការសិក្សារបស់កូនគាត់។

យោងទៅតាមជំនួយដែលមាន ការិយាល័យផ្នែកស្រាវជ្រាវនិងវាយតម្លៃកម្មវិធី ឬអ្នកវាយតម្លៃដែលមកពីក្រៅ ដែលនៅក្រោមការដឹកនាំរបស់ ការិយាល័យផ្នែកស្រាវជ្រាវនិងវាយតម្លៃកម្មវិធី នឹងប្រើវិធីដូចតទៅនេះដើម្បីវាយតម្លៃ ស្ថានការណ៍ នៃគោលបំណងនិងគោលបំណងបន្ទាប់បន្សំ ដែលបានសម្រេច៖ ការវាយតម្លៃ (មានរួមទាំង ការវាយតម្លៃអ្នកចាត់ការ ទូទាំងក្រសួង គ្រូបង្រៀន មាតាបិតា និង សិស្ស) មាតាបិតាដែលប្រជុំគ្នាជាក្រុមដើម្បីពិភាក្សាគ្នា ការធ្វើវិភាគលើសំណុំរឿង ក៏ដូចជា ការសង្កេតមើលពេលមានប្រជុំ និងពេលធ្វើសិក្ខាសាលា។

៦. **ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា** នឹងពង្រីកទំហំនៃការចូលរួមរបស់មាតាបិតា នៅតាមសាលា ដើម្បីធ្វើយ៉ាងណាឲ្យការចូលរួមរបស់មាតាបិតានិងអាណាព្យាបាលមានប្រសិទ្ធិភាព និងដើម្បីជួយដល់ការសហការ រវាងសាលា មាតាបិតានិងអាណាព្យាបាល ហើយនិងសហគមន៍ ដែលបានចូលរួម ដើម្បីឲ្យមានការរីកចំរើនដល់ការសិក្សារបស់សិស្ស តាមរយៈសកម្មភាព ដែលមានរៀបរាប់ដូចតទៅ៖

ក. ដោយមានជំនួយពី សាលា និង ការិយាល័យផ្នែកបង្ហាត់បង្រៀននិងការសិក្សា ដែលទទួលជំនួយ Title I, Part A ការិយាល័យផ្នែកទទួលខុសត្រូវ ការិយាល័យផ្នែកច្បាប់ Title I និង/ឬ ការិយាល័យ ទំនាក់ទំនងជាមួយមាតាបិតា ក្រុមគ្រួសារ សហគមន៍ និង ការសហការជាមួយក្រុមសាសនា និង ការិយាល័យផ្នែកកម្មវិធីសិក្សាពិសេស ក្រសួងអប់រំ ឬសាលា នឹងផ្តល់ជំនួយដល់មាតាបិតា អាណាព្យាបាលរបស់ក្មេង ដែលចូលរៀននៅតាមសាលា របស់ក្រសួងអប់រំ ដោយសមរម្យ ក្នុងការយល់ដឹងពីអ្វីៗដូចតទៅនេះ ដោយអនុវត្តទៅតាមការ រៀបរាប់នៅក្នុងវគ្គនេះ

-មុខវិទ្យាសិក្សា តាមខ្នាតគំរូរបស់រដ្ឋ
-ជោគជ័យលើការសិក្សារបស់សិស្ស តាមខ្នាតគំរូរបស់រដ្ឋ
-ការវាយតម្លៃ ពីរដ្ឋ និង ពីតំបន់ រួមទាំងការវាយតម្លៃតាមវិធីផ្សេងទៀត
-សេចក្តីតម្រូវពីច្បាប់ Title I, Part A
-វិធីតាមដានការរីកចម្រើនរបស់ក្មេង និង
-វិធីធ្វើការជាមួយបញ្ញវន្ត។

- ការិយាល័យផ្នែកប្រាក់ជំនួយ Title I នឹងរង់ចាំសហការ និង រៀបចំ ជាមួយការិយាល័យផ្សេងៗទៀត និង ក្រុមមាតាបិតា ដើម្បីផ្តល់ការណែនាំពន្យល់ និង សិក្ខាសាលា អំពីច្បាប់ Title I តាមច្បាប់មិនបន្សល់ក្មេង (No Child Left Behind Act)
- ជំរុញអោយសាលាអញ្ជើញមាតាបិតា/អាណាព្យាបាល ទៅចូលរួមក្នុងថ្ងៃហ្វឹកហ្វឺនបុគ្គលិក នៅពេលណាមានការ ពិភាក្សាពីអ្វីៗដូចខាងលើនេះ
- សំណូមពរឲ្យនាយកសាលា បន្ថែមសមាសភាគមាតាបិតា នៅថ្ងៃហ្វឹកហ្វឺនបុគ្គលិក នៅតាមសាលា
- គាំទ្រដល់ការចូលរួមរបស់មាតាបិតា នៅក្នុងអង្គប្រជុំ និង សិក្ខាសាលា ផ្សេងៗ ដូចជា ក្រុមប្រឹក្សាមាតាបិតារដ្ឋ PA (SPAC) អង្គប្រជុំអំពីការចូលរួមរបស់គ្រួសារនៅតាមតំបន់សិក្សា អង្គប្រជុំប្រចាំឆ្នាំ (ការរួបរួមសម្រាប់ការចូលរួមរបស់គ្រួសាររដ្ឋ PA) National Network of Partnership Schools, Good Schools Pennsylvania Conference, Pennsylvania Association of Federal Program Coordinator's Parent Awareness Training Conference, PA Parent Teacher Association (PTA) និង PA Governor's Institutes)។
- ប្រើមាតាបិតា/អាណាព្យាបាល ដែលបានចូលរួមក្នុងអង្គប្រជុំ និងសិក្ខាសាលា ឲ្យផ្តល់ការហ្វឹកហ្វឺនបង្វិលទិសដៅ ឬ សរសេររបាយការណ៍ ជាលក្ខណ្ឌនៃការឧបត្ថម្ភ។
- ផ្តល់ព័ត៌មានទៅមាតាបិតា/អាណាព្យាបាល ជាភាសាងាយស្រួលស្តាប់ និង យ៉ាងច្បាស់លាស់។
- ផ្តល់សិក្ខាសាលា ជាភាសាកំណើត ទៅគ្រួសារណាដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត តាមតែអាចធ្វើបាន។
- ចែកចាយសម្ភារៈពី ការិយាល័យបង្ហាត់បង្រៀននិងរៀនសូត្រ និងការិយាល័យផ្សេងៗទៀត រួមទាំង ការបកប្រែភាសា ទៅមាតាបិតានិងអាណាព្យាបាល តាមតែអាចធ្វើទៅបាន ដែលជាឯកសារយោងមានប្រយោជន៍ នៅផ្ទះ។

ខ. ដោយមានជំនួយពីសាលារៀនទាំងឡាយ ក្រសួងអប់រំនឹងផ្តល់សម្ភារៈ និង ការហ្វឹកហ្វឺនផ្សេងៗ ដើម្បីជួយ មាតាបិតា និង អាណាព្យាបាល ឲ្យចេះធ្វើការជាមួយកូនរបស់គាត់ ដើម្បីពង្រីកការសិក្សាឲ្យបានជោគជ័យ ដូចជា បង្កើតការហ្វឹកហ្វឺនផ្នែកអក្សរសាស្ត្រ និង ការប្រើបច្ចេកទេស ឲ្យបានសមរម្យ ដើម្បីនាំឲ្យមាតាបិតាចូលរួមក្នុងតំបន់ ដោយ៖

- បង្កើតសាកលវិទ្យាល័យមាតាបិតានៅក្នុងតំបន់ ដែលមានរួមទាំងការអប់រំមាតាបិតាជាច្រើនយ៉ាង ដែលផ្តល់ឲ្យដោយបុគ្គលិកសិក្សារបស់ក្រសួងអប់រំ ជាមួយនិងក្រុមជំនួយផ្សេងៗ ដោយមានរួមទាំងវិធីជួយកូននៅសាលារៀន និង ផ្នែកសិក្សាកុំព្យូទ័រ។
- សហការជាមួយអង្គការនានា ដែលមានរួមទាំង តែគ្មានកំណត់ ដូចជា៖ ការិយាល័យផ្នែកវត្តមានអវត្តមាននិងការគេចសាលា មជ្ឈមណ្ឌលផ្តល់ព័ត៌មាននិងជំនួយដល់មាតាបិតា និង ក្រុមប្រឹក្សាមាតាបិតានៃរដ្ឋផិនស៊ីវេញ៉ា ដើម្បី បង្កើតមជ្ឈមណ្ឌល/មូលដ្ឋាន/បន្ទប់ ផ្តល់ព័ត៌មានដល់មាតាបិតា នៅក្នុងសាលា។
- ផ្តល់ការហ្វឹកហ្វឺនផ្នែកកុំព្យូទ័រនិងការហ្វឹកហ្វឺនផ្សេងៗទៀតដែលជួយឲ្យមាតាបិតា/អាណាព្យាបាល យល់ពី FamilyNet (បណ្តាញគ្រួសារ) ជាមធ្យោបាយតាមដានការសិក្សារបស់កូនគាត់។
- ជំរុញឲ្យសាលា (តាមរយៈក្រសួងអប់រំ និង/ឬ នាយកប្រចាំតំបន់) អញ្ជើញ *យ៉ាងហោចណាស់* មាតាបិតាពីរនាក់ អ្នកតំណាងម្នាក់ និង អ្នកជំនួសម្នាក់ ឲ្យស្ម័គ្រចិត្តចូលរួមក្នុង កម្មវិធីច្បាប់ Title I មាតាបិតាជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា (PREP) របស់ក្រសួងអប់រំ។ ក្រសួងអប់រំនឹងផ្តល់ឱកាសហ្វឹកហ្វឺនផ្នែកកិច្ចការងារ អំពីអ្វីៗដែលទាក់ទងនឹងច្បាប់ Title I ដល់អ្នកតំណាង PREP ទាំងអស់ រៀងរាល់បីខែម្តង។
- ស្នើសុំឲ្យគេអញ្ជើញ មាតាបិតា Title I PREP របស់ក្រសួងអប់ ដើម្បីធ្វើការកែសម្រួលការចូលរួមរបស់ មាតាបិតា តាមច្បាប់ Title I (Title I Parent Engagement Policy) និង កិច្ចសន្យារវាងមាតាបិតានិងសាលា (Parent-School Compact) (តាមសេចក្តីត្រូវការ)។
- ប្រើបញ្ជីចុះឈ្មោះនិងចុះហត្ថលេខា (sign-in sheet) សម្រាប់ពេលប្រជុំ PREP ម្តងៗ ដើម្បីសាកសួរនាំបុគ្គលិកប្រចាំតំបន់ (នាយករងប្រចាំតំបន់ ឬ អ្នកតំណាង) នៅពេលណាសាលាគ្មានមាតាបិតាមកជាតំណាង។
- គាំទ្រដល់ការចូលរួមរបស់មាតាបិតាបីនាក់ ដែលមកពីតំបន់នីមួយៗ ឲ្យធ្វើជា ក្រុមប្រឹក្សាមាតាបិតា (PAC) សម្រាប់ច្បាប់ Title I របស់ក្រសួងអប់រំ។ គេនឹងតម្រូវឲ្យអ្នកតំណាង PAC មានអង្គប្រជុំរៀងរាល់ខែ នៅក្នុងតំបន់របស់ពួកគេ សម្រាប់អ្នកតំណាង PREP ប្រចាំតំបន់របស់ពួកគេ។ គេនឹងតម្រូវឲ្យអ្នកតំណាង PREP ផ្តល់ការហ្វឹកហ្វឺនពីការបង្វែទិសដៅ នៅតាមសាលារបស់ពួកគេ។
- គាំទ្រដល់សាលាក្នុងការ គ្រោងនិងអនុវត្ត សកម្មភាពនៅតាមសាលា ដូចជា រៀនអក្សរសាស្រ្ត និង គណិតវិទ្យា សម្រាប់គ្រួសារ នៅពេលយប់ និងសិក្ខាសាលា ផ្សេងៗ ដើម្បីជួយមាតាបិតានិងអាណាព្យាបាល ឲ្យយល់ពីរបៀបជួយកូនឲ្យមានជោគជ័យក្នុងការសិក្សា ដោយមានជំនួយពីការិយាល័យប្រចាំតំបន់ ការិយាល័យបង្ហាត់បង្រៀននិងរៀនសូត្រ  ការិយាល័យផ្នែកកម្មវិធីសិក្សាពិសេស និង ការិយាល័យគាំទ្រដល់ការបង្ហាត់បង្រៀននិងដឹកនាំ។ អភិវឌ្ឍន៍កម្មវិធីសិក្សា។
- ធ្វើយ៉ាងណាឲ្យមានបុគ្គលិកក្រសួងអប់រំ ដើម្បីរៀបចំ ការហ្វឹកហ្វឺន និងពន្យល់ណែនាំ សម្រាប់អង្គការផ្សេងៗ ដូចជា Title I PAC ក្រុមប្រឹក្សាសាលានិងមាតាបិតានៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា សមាគមមាតាបិតានិងសាលា ក្រុមធ្វើអោយមានសិទ្ធិទទួលការអប់រំនៅហ្វីឡាដែលហ្វ្យ៉ា ឥទ្ធិពលមាតាបិតា (PARENT POWER) និងការប្រជុំរបស់ មាតាបិតា ឬ អង្គការដែលនៅក្នុងសហគមន៍ ផ្សេងៗ។
- ផ្តល់ការពន្យល់ណែនាំ និងផ្តល់ឯកសារឲ្យបានសមរម្យ ជាភាសាដែលមិនមែនជាភាសាអង់គ្លេស។
- ស្រដៀងគ្នានឹងក្រុមប្រឹក្សាមាតាបិតាទូទាំងរដ្ឋផិនស៊ីវេញ៉ា មានការគាំទ្រដល់ការតាមដាននូវការចូលរួមរបស់មាតាបិតាក្នុងសាលាដោយ មាតាបិតា Title I PREP ប្រចាំតំបន់ និង បង្កើតឲ្យមានវិធីវាយតម្លៃ (ដោយមានជំនួយពី ការិយាល័យទទួលខុសត្រូវ) សម្រាប់ការប្រើសាលានីមួយៗដោយ អ្នកតំណាង PREP ប្រចាំតំបន់។

- ផ្តល់សិក្ខាសាលាខាងលើនេះ តាមទីកន្លែងផ្សេងៗនៅក្នុងសហគមន៍ ក្រៅពីសាលារៀន ដូចជា បណ្ណាល័យ អង្គការនានានៅក្នុងសហគមន៍ និង អង្គការសាសនា ដែលអាចធ្វើឲ្យក្រុមគ្រួសារមានភាពកក់ក្តៅ។

គ. ដោយមានជំនួយពីសាលារៀន និង មាតាបិតា/អាណាព្យាបាល ទាំងឡាយ ក្រសួងអប់រំនឹងបង្ហាត់គ្រូបង្រៀន បុគ្គលិកធ្វើការជាមួយសិស្សានុសិស្ស នាយកសាលា និង បុគ្គលិកផ្សេងៗទៀត អំពីវិធីប្រាស្រ័យទាក់ទង និងធ្វើ ការជាមួយ មាតាបិតា/អាណាព្យាបាល ក្នុងនាមជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា ការឲ្យតម្លៃដល់យោបល់របស់មាតាបិតា/អាណាព្យាបាល និងអំពីវិធីអនុវត្ត និងចាត់ការ កម្មវិធីសម្រាប់មាតាបិតា ព្រមទាំង កសាងចំណងមិត្តភាពរវាងមាតាបិតា/អាណាព្យាបាល និងសាលា ដោយ៖

- រៀបចំ និង អនុវត្ត នូវការពន្យល់ណែនាំជាបន្តបន្ទាប់ អំពីអ្វីៗដូចបានរៀបរាប់ខាងលើនេះ។
- ឲ្យមាតាបិតា/អាណាព្យាបាល ចូលរួមជាអ្នកបង្ហាត់ហ្វឹកហ្វឺន នៅក្នុងការហ្វឹកហ្វឺនជាមួយ អភិបាលសាលា គ្រូបង្រៀន និង បុគ្គលិកដទៃទៀត ដោយមានការរៀបចំចាត់ការពី ការិយាល័យគាំទ្រដល់ការបង្ហាត់បង្រៀននិងការដឹកនាំ ការបណ្តុះវិធីបង្ហាត់បង្រៀន និង ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និង ការសហការជាមួយក្រុមសាសនា។
- គ្រោងឲ្យមានអង្គប្រជុំជាធម្មតា រវាងការិយាល័យគាំទ្រដល់ការបង្ហាត់បង្រៀននិងការដឹកនាំ ការបណ្តុះវិធីបង្ហាត់បង្រៀន និង ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និង ការសការជាមួយក្រុមសាសនា ការិយាល័យផ្នែកកម្មវិធីសិក្សាពិសេស និង អ្នកតំណាងមាតាបិតានៃក្រុមប្រឹក្សាមាតាបិតាសម្រាប់ច្បាប់ Title I។

ឃ. តាមតែអាចធ្វើទៅបាន ក្រសួងអប់រំនឹង រៀបចំ និង បញ្ចូល កម្មវិធីចូលរួមរបស់មាតាបិតា និង សកម្មភាពផ្សេងៗ ជាមួយ កម្មវិធី មុនថ្នាក់មត្តេយ្យ (Head Start) អានជាដំបូង (Reading First) មណ្ឌលសិក្សាមុនថ្នាក់មត្តេយ្យ (Comprehensive Early Learning Center) អនាគតភ្លឺស្វាង (Bright Future) ចាប់ផ្តើមឡើងដំណាលគ្នា (Even Start) ផ្ទះសម្រាប់កូននិងមាតាបិតា (Parent Child Home) និង ពីក្នុងអង្រឹងទៅក្នុងថ្នាក់រៀន (Cradle to Classroom) និងកម្មវិធីផ្សេងៗទៀត ព្រមទាំងធ្វើឲ្យមានសកម្មភាពផ្សេងៗទៀត ដូចជា មណ្ឌលផ្តល់ព័ត៌មានដល់មាតាបិតា ដែលនឹងជួយលើកទឹកចិត្ត ហើយជួយដល់មាតាបិតា/អាណាព្យាបាល ឲ្យមានការចូលរួមឲ្យបានពេញលេញ ក្នុងការបង្ហាត់បង្រៀនដល់កូន ដោយ៖

- រៀបចំអង្គប្រជុំរវាងការិយាល័យផ្សេងៗ ទៅតាមត្រីមាស ដូចមានរៀបរាប់នៅវគ្គទី៤ខាងលើនេះ។
- រួមបញ្ចូលទាំង មាតាបិតា/អាណាព្យាបាល និងបុគ្គលិកនៃកម្មវិធីខាងលើនេះក្នុងសកម្មភាព ក្រុមប្រឹក្សា មាតាបិតា។
- ផ្តល់ជំនួយភាសាដល់ សិស្សមុនថ្នាក់មត្តេយ្យ និង ក្រុមគ្រួសាររបស់ពួកគេ ដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត

ង. ក្រសួងអប់រំនឹង រៀបចំតាមការរៀបរាប់ខាងក្រោម ដើម្បីធ្វើយ៉ាងណាឲ្យមានការផ្ញើជូនដល់មាតាបិតា/អាណាព្យាបាល នូវព័ត៌មានដែលទាក់ទងទៅនិងកម្មវិធីរបស់សាលានិងមាតាបិតា អង្គប្រជុំ និងសកម្មភាពនានា ឲ្យងាយស្រួលយល់

និង មានលក្ខណៈដូចៗគ្នា មានរួមទាំងតាមលក្ខណៈផ្សេងៗទៀត តាមការស្នើសុំ និង ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ជាភាសាដែលមាតាបិតាអាចយល់បាន៖

- ផ្តល់ការទាក់ទងជាភាសាដែលងាយយល់ និង ច្បាស់លាស់ តាមតែអាចធ្វើទៅបាន។
- ផ្តល់សន្ទានុក្រមសម្រាប់ពន្យល់ ពាក្យកាត់ ឬ ពាក្យមិនច្បាស់លាស់។
- ផ្តល់ឯកសារជំនួយសម្រាប់អ្នកដែលមិនអាចមើលឃើញច្បាស់ ដូចជាសរសេរជាអក្សរធំៗ ទៅតាមការស្នើសុំ តាមតែអាចធ្វើទៅបាន។
- ផ្តល់ពាក្យសង្ខេប និងសេចក្តីផ្តើម ដល់ឯកសារជាផ្លូវការ។
- ផ្តល់ កាសែតសម្លេង ឬ កាសែតរូបភាព នៃឯកសារខ្លះៗ។
- ផ្តល់ការនិយាយពន្យល់ឲ្យបានក្បោះក្បាយ ពីឯកសារសរសេរផ្សេងៗ នៅពេលណាមានការស្នើសុំ។
- ផ្តល់ការបកប្រែជាភាសា ទៅក្រុមគ្រួសារណាដែលភាសាកំណើតមិនមែនជាភាសាអង់គ្លេស ដល់កន្លែង ឬ តាមទូរស័ព្ទ ទៅតាមការសមរម្យ។
- ចែកចាយលិខិតជូនដំណឹងឲ្យបានច្រើន អំពីឱកាសសម្រាប់ មាតាបិតា និង កូន ឲ្យមានការពិសោធន៍នូវ ពិធីវប្បធម៌ សកម្មភាព និង កម្មវិធី ផ្សេងៗទៀត។
- បិទប្រកាស នូវការទាក់ទងដូចរៀបរាប់ខាងលើនេះ នៅក្នុង វ៉ិបសៃ របស់ក្រសួងអប់រំ
- ផ្តល់ការទាក់ទងដោយប្រើលេខទូរស័ព្ទស្វ័យប្រវត្តិ ការទាក់ទងជាមួយមាតាបិតា (parent link) និង វ៉ិបសៃ របស់សាលា
- បង្កើតវិធីណាមួយដើម្បីប្រមូលព័ត៌មានប្រកាសផ្សាយ និង ព័ត៌មានដែលទាក់ទងគ្នា។
- ស្នើសុំ ដៃគូនៅក្នុងសហគមន៍ ដែលមានរួមទាំង បណ្ណាល័យ មណ្ឌលលេងកំសាន្ត សមាគមក្នុងសហគមន៍ និង អង្គការសាសនាផ្សេងៗ ឲ្យជួយផ្សព្វផ្សាយព័ត៌មាន។
- ផ្សាយកំណត់ហេតុព័ត៌មានផ្សេងៗ តាមទូរទស្សន៍ផ្សាយដំណឹងជាសាធារណៈរបស់ក្រសួងអប់រំ PS-TV តាមស្ថានីយ៍សាធារណៈផ្សេងៗ និង តាមវិទ្យុ តាមតែអាចធ្វើទៅបាន។
- ដាក់ឲ្យមានការចុះផ្សាយតាមសារព័ត៌មានប្រចាំតំបន់ រួមទាំង សារព័ត៌មានជាភាសាកំណើត សារព័ត៌មានផ្នែកសិក្សា និង សារព័ត៌មានប្រចាំតំបន់ តាមតែអាចធ្វើទៅបាន។

## ផ្នែកទី៣ ការផ្តល់ដំណឹង និង ការចូលរួមរបស់មាតាបិតា ជាមួយការកែសម្រួលសម្រាប់សាលា ដែលមានការកែរតម្រូវ ឬស្ថានភាពកសាងឡើងវិញ

ក. *គោលបំណង។* គណកម្មាធិការកែទម្រង់សាលាដឹងថា ជាការទទួលខុសត្រូវរបស់ក្រសួងក្នុងការប្រតិបត្តិតាមការតម្រូវរបស់សហព័ន្ធ ក្រោមច្បាប់មិនបន្សល់ក្មេង (No Child Left Behind) ដែលជាច្បាប់ឆ្នាំ២០០១ (“NCLB”) នៅសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ៊ា ដែលទាក់ទងនិងការចូលរួមរបស់មាតាបិតាក្នុងការធ្វើគម្រោងការ និង ប្រតិបត្តិការណ៍ នៃការកែសម្រួលដូចបានចែងក្នុងច្បាប់ 20 U.S.C. § 6316(b)(7) និង (8) សម្រាប់សាលាដែលត្រូវការកែតម្រូវ និង ស្ថានការណ៍រៀបចំជាថ្មី ក្រោមច្បាប់ NCLB។ ច្បាប់នេះរៀបចំវិធីផ្សេងៗ ដើម្បីធ្វើយ៉ាងណាឲ្យ លិខិតជូនដំណឹងទៅមាតាបិតា និង ឱកាសអោយ មាតាបិតា និង គ្រូបង្រៀន ចូលរួមក្នុងសកម្មភាពកែសម្រួលសំខាន់ៗទាំងនេះ។

ខ. *ការផ្ទេរការទទួលខុសត្រូវ។* រក្សាទុកក្រុមចាត់ចែងជាន់ខ្ពស់និងគណកម្មាធិការកែទម្រង់សាលាផ្ទាល់ មុខនាទីនៃការសម្រេចចិត្តរបស់គេយោងទៅតាម ច្បាប់សាលារដ្ឋនៅរដ្ឋផិនសល់វេញ៉ា (Pennsylvania Public School Code) មានរួមទាំង តែគ្មានកំណត់ទៅនឹងច្បាប់ 24 P.S. §§ 5-510, 6-693 និង 6-696 គណកម្មាធិការកែទម្រង់សាលាបង្គាប់អោយ៖

១. សាលាដែលត្រូវមានសកម្មភាពកែតម្រូវ

ក. ក្រសួងអប់រំនឹងបោះពុម្ព ហើយចែកចាយព័ត៌មានដែលទាក់ទងនឹងសកម្មភាពកែតម្រូវដែលក្រសួងអប់រំធ្វើតាមមាត្រាលេខ 6316(b)(7) នៃច្បាប់ NCLB នៅសាលា

(១) ទៅអោយសាធារណៈជន និង មាតាបិតារបស់សិស្សម្នាក់ៗដែលរៀននៅសាលា ដែលជាប់ទាក់ទងដល់ សកម្មភាពកែតម្រូវ

(២) ទៅតាមការអាចយល់បាននិងតាមលក្ខណៈដូចៗគ្នា និង តាមភាសាដែលមាតាបិតាអាចយល់ តាមតែអាចធ្វើទៅបាន និង

(៣) តាមរយៈវិធីផ្សេងៗ ដូចជា អ៊ិនធ័រណេត ក្រសួងផ្សាយពត៌មាន និង ក្រសួងសាធារណៈដែលរួមទាំង ទំព័រវ៉ិបសៃរបស់ក្រសួងអប់រំ។

២. សាលាដែលមានគម្រោងការរៀបចំថ្មី

ក. ក្រសួងអប់រំនឹង

(១) បើសិនជា ក្រោយពេលមួយ (១) ឆ្នាំនៃសកម្មភាពកែតម្រូវ តាមមាត្រាលេខ 20 U.S.C. § 6316(b)(7) ហើយសាលានៅតែធ្វើមិនបានតាមការរីកចម្រើនប្រចាំឆ្នាំ បន្ទាប់មកក្រសួងអប់រំនឹងធ្វើគម្រោងការ និងធ្វើការរៀបចំដើម្បីធ្វើតាមមធ្យោបាយផ្សេងទៀតដែលមានចែងក្នុងមាត្រាលេខ 20 U.S.C. § 6316(b)(8)(B)

(២) ផ្តល់លិខិតជូនដំណឹងអោយបានឆាប់បំផុតទៅគ្រូនិងមាតាបិតា ពេលណាសាលាមានការតម្រូវអោយមានគម្រោងការថ្មី តាមមាត្រាលេខ 6316(b)(8)(A) និង (B) ហើយ

(៣) ផ្តល់អោយគ្រូនិងមាតាបិតានូវឱកាសគ្រប់គ្រាន់ដើម្បី

ក. មានយោបល់មុននឹងធ្វើសកម្មភាពអ្វីមួយ តាមមាត្រាលេខ 6316(b)(8)(A) និង (B) ហើយ

ខ. ចូលរួមក្នុងការបង្កើតគម្រោងការ តាមមាត្រាលេខ 6316(b)(8)(A)(iii) (ផ្តល់ជំនួយសម្រាប់ការគ្រប់គ្រងថ្មីដល់សាលា)។

១. ករណីយកិច្ច

a. ការិយាល័យនាយកប្រតិបត្តិនៃក្រសួងអប់រំ សហការជាមួយ ការិយាល័យផ្នែកទំនាក់ទំនង និង នាយកផ្នែកសិក្សាធិការ ប្រសិនបើចាំបាច់ នឹងផ្តល់លិខិតជូនដំណឹងទៅមាតាបិតា តាមការតម្រូវ ដោយច្បាប់ NCLB ហើយច្បាប់នេះ នឹងរៀបចំ ឧបត្ថម និង អនុវត្តវិធីចូលរួមរបស់មាតាបិតា ដែលតម្រូវឲ្យដោយច្បាប់ NCLB នេះ។

b. នៅពេលណាដែលអាចធ្វើទៅបាន ក្រសួងអប់រំនឹងបញ្ចូលលិខិតជូនដំណឹង អង្គប្រជុំ ការតម្រូវ ផ្សេងៗទៀត ដែលតម្រូវអោយធ្វើដោយច្បាប់ NCLB និង ច្បាប់នេះ ជាមួយលិខិតជូនដំណឹង ទៅមាតាបិតា ដែលមានពីមុនមក និងវិធីចូលរួមដែលបានធ្វើរួចមកហើយ តាមច្បាប់ NCLB ដូច ជា គម្រោងការ និង ច្បាប់ ដែលធ្វើអោយសាលាមានការរីកចម្រើន។

c. ទំនាក់ទំនងជាមួយមាតាបិតានិងធ្វើឡើងតាមមាត្រាលេខ 34 C.F.R. §200.36 ជាមួយនឹងការ ព្រមព្រៀងដែលមានចែងក្នុងកិច្ចសន្យា ដូចមានចែងក្នុងមាត្រាលេខ 34 C.F.R. §200.36(c)(1) យោងទៅតាមកាលៈទេសៈក្នុងតំបន់ អភិបាលក្រសួងអប់រំនិងសាលាអាចជ្រើសរើសផ្តល់ព័ត៌មាន ដែលមានរួមទាំង លិខិតជូនដំណឹង ទៅសាលាសម្រាប់ចែកចាយទៅមាតាបិតា។

៤. ការកំណត់ទុក

a. សមត្ថភាពក្នុងការសម្រេចចុងក្រោយបង្អស់ដែលជាប់ទាក់ទងជាមួយសាលាដែលមាន សកម្មភាព កែតម្រូវ ឬស្ថានភាពរៀបចំគម្រោងការថ្មី គឺនៅលើគណកម្មាធិការកែទម្រង់សាលា ក្រោមច្បាប់ NCLB និង Pennsylvania Public School Code សូមមើលមាត្រាលេខ 24 P.S. 5-510, 6-693, 6-696។ ដើម្បីអាចអនុវត្តនូវគោលបំណងនៃការកែសម្រួលរបស់គេស្របច្បាប់ គណ កម្មាធិការកែទម្រង់សាលាមានសិទ្ធិគួរ ឬមិនគួរធ្វើអ្វីៗ ដែលទាក់ទងដល់រឿងទាំងអស់នេះ។

b. យោងទៅតាមការមិនធ្វើតាមទាំងស្រុង ក្រសួងអប់រំនឹងរិះរកផ្តល់ឳកាសឲ្យមាតា បិតាអាចចូលរួម ដូចមានចែងក្នុងច្បាប់ NCLB ក្នុងការសម្រេចនូវគម្រោងការរៀបចំថ្មី ដែលទាក់ទងដល់សាលា របស់កូនគាត់។ មាតាបិតាអាចចូលរួមតាមរយៈអ្នកតំណាងរបស់គាត់ ដែលមានរួមទាំងសហ គមន៍ និង ក្រុមគាំទ្រ។ គណកម្មាធិការកែទម្រង់សាលា សុំឲ្យមានការចូលរួម ដោយក្រុមគាំទ្រ ទាំងអស់ ដែលស៊ូប្តូរចំពោះការរីកចម្រើនរបស់សាលានីមួយៗ ហើយរង់ចាំធ្វើការជាមួយមាតា បិតា និង ក្រុមគាំទ្រផ្សេងទៀតទាំងអស់ របស់យើង។

c. ការអនុវត្តន៍ច្បាប់នេះនឹងមិនតម្រូវឲ្យមានការប្រែប្រួលអ្វីដល់កិច្ចព្រមព្រៀងដែលមានពីមុនមក ដែលកិច្ចព្រមព្រៀងនេះជារបស់ក្រសួងអប់រំ ឬកិច្ចព្រមព្រៀងដែលក្រសួងអប់រំគឺជាសមាជិក តាមថ្ងៃដែលចាប់ផ្តើមជាផ្លូវការ។

៥. និយមន័យ

a. “សកម្មភាពកែតម្រូវ“ មានន័យដូចបានបញ្ជាក់ក្នុងមាត្រាលេខ 20 U.S.C. §6316(b)(7)(A) – (E) នៃច្បាប់ NCLB។

b. “គម្រោងការរៀបចំថ្មី“ មានន័យដូចបានបញ្ជាក់ក្នុងមាត្រាលេខ 20 U.S.C. §6316(8) ហើយ “ការកាន់កាប់ជំនួស“ មានន័យដូចបានបញ្ជាក់ក្នុងមាត្រាលេខ 20 U.S.C. §6316(b)(8)(B)

## ផ្នែកទី៤ ផ្នែកទាំងឡាយនៃច្បាប់របស់ក្រសួងអប់រំ អំពីការចូលរួមរបស់មាតាបិតា

- នាំឲ្យមាតាបិតា/អាណាព្យាបាល ចូលរួមក្នុងការរៀបចំ ការហ្វឹកហ្វឺនគ្រូបង្រៀន នាយកសាលា និងបញ្ញវន្តផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធិភាពនៃការហ្វឹកហ្វឺន
- ផ្តល់ការហ្វឹកហ្វឺនផ្នែកអក្សរសាស្ត្រតាមការចាំបាច់ ដល់មាតាបិតា/អាណាព្យាបាល ដែលទទួលជំនួយពីកម្មវិធី Title 1 Even Start និង Family Literacy (អក្សរសាស្ត្រសម្រាប់គ្រួសារ)
- បង់ថ្លៃឲ្យបានសមរម្យ ទៅលើការចាយវាយសម្រាប់សកម្មភាពនានា ដែលមានទាក់ទងទៅលើការចូលរួមរបស់មាតាបិតា រួមទាំង ការដឹកនាំ និង ថ្លៃជួលមើលក្មេង ដើម្បីឲ្យ មាតាបិតា/អាណាព្យាបាល មានលទ្ធភាពអាចចូលរួមក្នុងអង្គប្រជុំនៅសាលា និង ការហ្វឹកហ្វឺននានា ទៅតាមចំនួនប្រាក់ដែលមាន
- ហ្វឹកហ្វឺនមាតាបិតា/អាណាព្យាបាល ដើម្បីបង្កើននូវការចូលរួមពី មាតាបិតា/អាណាព្យាបាល ផ្សេងទៀត
- រៀបចំអង្គប្រជុំនៅសាលាតាមពេលវេលាខុសៗគ្នា ឬបើកអង្គប្រជុំនៅផ្ទះ រវាង គ្រូបង្រៀន ឬ បញ្ញវត្ត ផ្សេងៗ ដែលមានការចូលរួមផ្ទាល់ជាមួយក្មេង ជាមួយមាតាបិតា/អាណាព្យាបាល ដែលមិនអាចចូលរួមប្រជុំនៅសាលាបាន ដើម្បីបង្កើនការចូលរួមឲ្យកាន់តែច្រើនពីមាតាបិតាក្នុងអប់រំរបស់កូន។
- ការស្រាវជ្រាវ ការអនុម័ត និង ការអនុវត្ត តាមគំរូណាដែលនឹងជួយបង្កើននូវការចូលរួមរបស់មាតាបិតា
- បង្កើតឲ្យមានតំណាង និង ក្រុមប្រឹក្សាទូទាំងក្រសួង ដើម្បីផ្តល់យោបល់ទៅលើរឿងរ៉ាវគ្រប់យ៉ាង ដែលទាក់ទងទៅលើសកម្មភាពនៃការចូលរួមរបស់មាតាបិតា នៅក្នុងកម្មវិធីច្បាប់ Title 1, Part A
- បង្កើតឲ្យមានមុខងារសមរម្យ សម្រាប់អង្គការនៅក្នុងសហគមន៍ និង ពាណិជ្ជកម្ម ផ្សេងៗ រួមទាំង អង្គការសាសនា ក្នុងសកម្មភាពនៃការការចូលរួមរបស់មាតាបិតា និង
- ផ្តល់ជំនួយសមរម្យផ្សេងៗ ទៅលើសកម្មភាពនៃការចូលរួមរបស់មាតាបិតា តាមមាត្រាលេខ ១១១៨ តាមការស្នើសុំរបស់មាតាបិតា/អាណាព្យាបាល។

## ផ្នែកទី៥ ការអនុម័ត

ច្បាប់នៃការចូលរួមរបស់មាតាបិតាទូទាំងក្រសួងនេះ បានអភិវឌ្ឍន៍រួមគ្នាជាមួយ និងមានការយល់ព្រមពី មាតាបិតា/ អាណាព្យាបាល របស់ក្មេងដែលចូលរួមក្នុងច្បាប់ Title I, Part A ដោយមានភ័ស្តុតាងតាមការប្រជុំ នៅថ្ងៃទី១៩ ខែមេសា និង ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០។

ច្បាប់នេះ ត្រូវបានអនុម័តដោយ**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា** នៅ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ហើយនិងប្រើការបានក្នុងកំឡុងពេលឆ្នាំសិក្សាមួយឆ្នាំ។ ក្រសួងអប់រំនឹងចែកជូនច្បាប់នេះទៅមាតាបិតា/អាណាព្យាបាល ទាំងអស់របស់ក្មេងដែលចូលរួមក្នុងច្បាប់ Title I, Part A ឲ្យបានមុនថ្ងៃ ឬ នៅថ្ងៃ **ទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។**

______________________________
(Signature of Authorized Official)

______________________________
(Date)

ឯកសារយោង៖

| | |
|---|---|
| NCLB: | 20 U.S.C. §§6316(b) (7), (8) |
| C.F.R. | 34 C.F.R. §200.36 |
| State School Code: | 24 P.S. §1-101 et seq., including 24 P.S. §§6-693, 6-696 |